01027413

លេខ: D117/1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des Tribunaux cambodgiens

ឯកសារបានទទួល
DOCUMENT RECEIVED/DOCUMENT REÇU
ថ្ងៃ ខែ ឆ្នាំ (Date of receipt/date de reception): 16 / 09 / 2014
ម៉ោង (Time/Heure): 14:56
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

ការិយាល័យសហចៅក្រមស៊ើបអង្កេត
**Office of the Co-Investigating Judges**
**Bureau des co-juges d'instruction**

**សំណុំរឿងលេខ: ០០៣/០៧-០៩-២០០៩/អ.វ.ត.ក--ក.ស.ច.ស**

ចំពោះមុខ: **សហចៅក្រមស៊ើបអង្កេត**

កាលបរិច្ឆេទ: **ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤**

ភាសា: **ខ្មែរ/អង់គ្លេស [ភាសាដើម អង់គ្លេស]**

ចំណាត់ថ្នាក់ឯកសារ: **សម្ងាត់ ប្តូរទៅជាសាធារណៈ**

***ដីកាសម្រេចលើសំណើរបស់ជនសង្ស័យទាក់ទងនឹង***
***ដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់***

**ផ្ញើជូន**

**សហព្រះរាជអាជ្ញា**
ជា លាង
Nicholas KOUMJIAN

**សហមេធាវីតំណាងជនសង្ស័យ**
អាង ឧត្តម
Michael KARNAVAS

**សហមេធាវីដើមបណ្តឹងរដ្ឋប្បវេណី**
ហុង គីមសួន
គីម ម៉េងឃី
ម៉ុច សុវណ្ណារី
សំ សុគង់
ទី ស្រីនណា
វ៉ែន ពៅ

Philippe CANONNE
Annie DELAHAIE
Laure DESFORGES
Ferdinand DJAMMEN-NZEPA
Nicole DUMAS
Isabelle DURAND
Françoise GAUTRY
Martine JACQUIN
Christine MARTINEAU
Barnabe NEKUI
Lyma NGUYEN
Nushin SARKARATI
Fabienne TRUSSES

01027414



**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤ ("ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក")។

**បានឃើញ** ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥០០, ៥០១, ៥០៣, ៥០៥, ៥០៦, ៥០៧ និង ៥០៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ**មាត្រា ៥ និង ៧ នៃកិច្ចព្រមព្រៀងរវាងអង្គការសហប្រជាជាតិ និងរាជរដ្ឋាភិបាលកម្ពុជា ទាក់ទងនឹងការកាត់សេចក្តីនៅក្រោមច្បាប់កម្ពុជា នូវឧក្រិដ្ឋកម្មដែលប្រព្រឹត្តឡើងនៅក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ចុះថ្ងៃទី ៦ ខែ មិថុនា ឆ្នាំ ២០០៣ ("កិច្ចព្រមព្រៀង អ.វ.ត.ក")។

**បានឃើញ**មាត្រា ២៣ ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក។

**បានឃើញ**វិធាន ១, ៤១, ៥៥ និង ៧២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក ("វិធានផ្ទៃក្នុង")។

**បានពិចារណាទៅលើ***សំណើរបស់មាស មុត សុំព័ត៌មានទាក់ទងនឹងសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ("សំណើសុំព័ត៌មាន")[2]។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នាចុះបញ្ជីនៅថ្ងៃទី៧ និងថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣។

---

[1] សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ថ្ងៃទី ២០ ខែ វិច្ឆិកា ឆ្នាំ ២០០៨។ សំណុំរឿង ០០៣ ឯកសារ D1/1 *ការជូនដំណឹងអំពីការដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើកទី ២ របស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីទី* ថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩ ។

[2] សំណុំរឿង ០០៣ ឯកសារ D117 *សំណើរបស់មាស មុត សុំព័ត៌មានទាក់ទងនឹងសុពលភាពនៃដីកាកោះដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ចុះថ្ងៃទី ១៣ ខែ សីហា ឆ្នាំ ២០១៤។

## សារណា

១. សំណើសុំព័ត៌មាន លើកឡើងពីសំណួរនានាទាក់ទងនឹងសុពលភាពនៃដីកាកោះណាមួយដែលចេញដោយសហចៅក្រមស៊ើបអង្កេតអន្តរជាតិក្នុងគោលបំណងដើម្បីចោទប្រកាន់មាស មុត ("ជនសង្ស័យ")។ ដោយបញ្ជាក់ថា *"សុពលភាពនៃដីកាកោះដែលត្រូវបានចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ មិនត្រូវបានកំណត់ឱ្យបានច្បាស់លាស់នៅក្នុងកិច្ចព្រមព្រៀង ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុងឡើយ"* មេធាវីជនសង្ស័យ ស្នើសុំសំអាងផ្លូវច្បាប់ពីសហចៅក្រមស៊ើបអង្កេតម្នាក់ៗទាក់ទងនឹងសុពលភាពនៃដីកាកោះបែបនេះ ដើម្បីផ្តល់ប្រឹក្សាប្រកបដោយអត្ថន័យជូនជនសង្ស័យ ជាពិសេសនៅក្នុងករណីដែលមានបណ្តឹងឧទ្ធរណ៍ណាមួយនៅចំពោះមុខអង្គបុរេជំនុំជម្រះ("អ.ប.ជ")[3]។

២. សំណើសុំព័ត៌មាន ក៏បែងចែកភាពខុសគ្នារវាងសេចក្តីសម្រេចមុនៗរបស់ អ.ប.ជ នៅក្នុងសំណុំរឿង ០០២ ដែលបញ្ជាក់អំពីសុពលភាពនៃកិច្ចស៊ើបសួរដែលអនុវត្តដោយចៅក្រមតែម្នាក់ ជាពិសេសដោយផ្អែកលើមូលដ្ឋានថា *"ការកោះហៅលោក មាស មុត ដើម្បីធ្វើការចោទប្រកាន់ មិនពាក់ព័ន្ធនឹងបញ្ហាថាតើការស៊ើបអង្កេតនឹងត្រូវបន្ត ឬយ៉ាងណានោះឡើយ ព្រោះការកោះហៅនេះមិនមែនជាកិច្ចស៊ើបអង្កេតទេ"*[4]។

## ពិភាក្សា

៣. សុពលភាពនៃដីកាកោះហៅជនសង្ស័យណាម្នាក់ដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ គឺមានចែងយ៉ាងច្បាស់នៅក្នុងច្បាប់ជាធរមាន ជាពិសេសនៅក្នុងមាត្រា ៥ និង ៧ នៃកិច្ចព្រមព្រៀង អ.វ.ត.ក មាត្រា២៣ថ្មី នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងវិធានផ្ទៃក្នុង ៧២[5]។ ការអះអាងរបស់មេធាវីជនសង្ស័យដែលថា ការកោះហៅជនសង្ស័យណាម្នាក់ឱ្យមកបង្ហាញខ្លួនលើកដំបូង មិនមែនជាកិច្ចស៊ើបអង្កេតទេ ដូច្នេះមិនស្ថិតនៅក្នុងក្របខណ្ឌនៃវិធាន

---

[3]សំណើសុំព័ត៌មាន ទំព័រ ១។

[4]សំណើសុំព័ត៌មាន ទំព័រ ២។

[5]*សូមមើលផងដែរ* សំណុំរឿង 004 ឯកសារ D212/1 *ការបំភ្លឺរបស់សហចៅក្រមស៊ើបអង្កេតអន្តរជាតិអំពីសុពលភាពនៃដីកាកោះដែលចុះហត្ថលេខាដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់* ថ្ងៃទី១ ខែកញ្ញា ឆ្នាំ ២០១៤ ("ការបំភ្លឺអំពីសុពលភាពនៃដីកាកោះ")។

ផ្ទៃក្នុង ៧២ នោះ គឺជាការអះអាងដែលគ្មានមូលដ្ឋាន។ ស.ច.ស.អន្តរជាតិ បានដោះស្រាយបញ្ហានេះរួចហើយនៅក្នុងសំណុំរឿង ០០៤ ដោយក្នុងនោះ គាត់បានយល់ឃើញថា *"វិធានផ្ទៃក្នុង ៧២ ដែលចែងអំពីករណីខ្វែងយោបល់គ្នារវាងសហចៅក្រមស៊ើបអង្កេត ច្បាស់ណាស់ពិតជាអនុវត្តទៅលើកិច្ចទាំងអស់ដែលអនុវត្តដោយ ស.ច.ស នៅក្នុងការបំពេញកិច្ចស៊ើបសួរ"* ហើយបានសន្និដ្ឋានថា *"វិធានផ្ទៃក្នុង ៧២ មិនបង្កើតឲ្យមានករណីលើកលែង ឬខុសប្លែកគ្នាទេ ទាក់ទងនឹងដីកាកោះហៅជនសង្ស័យនានាសម្រាប់ការបង្ហាញខ្លួនលើកដំបូង"*[6]។

៤. គោលការណ៍នេះត្រូវបានបញ្ជាក់យ៉ាងច្បាស់ដោយ អ.ប.ជ ដែលបានសន្និដ្ឋានថា អំណាចរបស់ ស.ច.ស.អន្តរជាតិ ក្នុងការចេញដីកាកោះហៅជនសង្ស័យណាម្នាក់ដែលមានសុពលភាពតែម្នាក់ឯង"*មានចែងយ៉ាងច្បាស់នៅក្នុងបទប្បញ្ញត្តិនៃកម្រងច្បាប់ អ.វ.ត.ក និងយុត្តិសាស្ត្ររបស់ អ.ប.ជ"*[7]។

**តាមសំអាងហេតុខាងលើ ខ្ញុំ MARK B. HARMON ៖**

៥. **បញ្ជាក់ថា** អនុលោមតាមច្បាប់ជាធរមាន ដីកាកោះហៅជនសង្ស័យណាម្នាក់ដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ គឺមានសុពលភាព និងជាប់កាតព្វកិច្ច។

៦. **ណែនាំឲ្យ**ក្រឡាបញ្ជីរបស់ ក.ស.ច.ស ផ្តល់ជូនមេធាវីជនសង្ស័យនូវសំណៅកោសលុបនៃឯកសារ D212/1 និង A122/6.1/3 ដែលបានចេញនៅក្នុងសំណុំរឿង ០០៤ និងបានដកស្រង់នៅក្នុងដីកាសម្រេចនេះ។

ភ្នំពេញ ថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ២០១៤

**ចៅក្រម Mark B. Harmon**
**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**
**International Co- Investigating Judge**
**Co-juge d'instruction International**

---

[6]ការបំភ្លឺអំពីសុពលភាពនៃដីកាកោះ កថាខណ្ឌ ៩។

[7]សំណុំរឿង ០០៤ ឯកសារ A122/6.1/3 *សេចក្តីសម្រេចលើសំណើបន្ទាន់[កោសលុប]* ថ្ងៃទី ១៥ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ១៤ ។